សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការផ្សព្វផ្សាយសេវាធនាគារ និងហិរញ្ញវត្ថុផ្លូវការប្រកបដោយទំនួលខុសត្រូវ និងកិច្ចការពារអតិថិជន នៅខេត្តរតនគិរី

ខេត្តរតនគិរី (ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤)៖ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានសហការរៀបចំសិក្ខាសាលាថ្នាក់ខេត្តស្តីពី៖ «ការផ្សព្វផ្សាយសេវាធនាគារ និងហិរញ្ញវត្ថុផ្លូវការប្រកបដោយទំនួលខុសត្រូវ និងកិច្ចការពារអតិថិជន» ជាលើកទី១ ជូនដល់អាជ្ញាធរមូលដ្ឋាន នៅក្នុងក្រុងបានលុង និងស្រុកអូរជុំ នៃខេត្តរតនគិរី នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤។

សិក្ខាសាលាថ្នាក់ខេត្តនេះ បានរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តម ខិន ណៃល** អភិបាលរងខេត្តរតនគិរី ព្រមទាំង**លោក គួច ចៅចេក** សមាជិកក្រុមប្រឹក្សានៃសមាគមធនាគារនៅកម្ពុជា និង **លោកជំទាវ ឌិត នីតា** ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ សិក្ខាសាលានេះក៏មានការចូលរួមពីវាគ្មិនកិត្តិយស **លោក ញ៉ាង តង** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង/ស្រុក ឃុំ/សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ និង**លោក ទឹម មុនីរតន៍** អនុប្រធានមន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ខេត្តរតនគិរី លោកនាយករងសាខាធនាគារជាតិនៃកម្ពុជាខេត្តរតនគិរី ព្រមទាំងលោក/លោកស្រីអភិបាលរងក្រុងបានលុង មេឃុំ ជំទប់ឃុំ មេប៉ុស្តិ៍ និងមេភូមិ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធផ្សេងទៀតប្រមាណជាង ១០០នាក់។

គោលបំណងនៃអង្គសិក្ខាសាលា គឺដើម្បីផ្សព្វផ្សាយពីបច្ចុប្បន្នភាព ទិសដៅនៃការផ្តល់សេវាហិរញ្ញវត្ថុផ្លូវការ ពិគ្រោះយោបល់លើបញ្ហាប្រឈម សំណូមពរ និងដំណោះស្រាយដើម្បីពង្រឹងប្រសិទ្ធភាពការផ្តល់ និងទទួលសេវាហិរញ្ញវត្ថុផ្លូវការ ចូលរួមទប់ស្កាត់ការផ្តល់កម្ចីក្រៅផ្លូវការ និងបញ្ជ្រាបការយល់ដឹងពីអត្ថប្រយោជន៍នៃការប្រើប្រាស់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។

**លោកជំទាវ ឌិត នីតា** ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា មានប្រសាសន៍ថា បច្ចុប្បន្ននេះ វិស័យមីក្រូហិរញ្ញនៅកម្ពុជានៅតែបន្តរក្សាបានកំណើននិងស្ថិរភាពតាមរយៈការផ្តល់សេវាប្រកបដោយបរិយាបន្ន ជាមួយស្មារតីទទួលខុសត្រូវខ្ពស់ និងកិច្ចការពារអតិថិជន ស្របតាមយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ ២០១៩-២០២៥។ វិស័យមីក្រូហិរញ្ញវត្ថុក៏បាន ពង្រឹកប្រតិបត្តិការរបស់ខ្លួន ព្រមទាំង

បានផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដល់ទីជនបទ ជាពិសេសបងប្អូនជនជាតិដើមភាគតិច។ គិតត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ វិស័យមីក្រូហិរញ្ញវត្ថុបានជួយគាំទ្រដល់ប្រជាពលរដ្ឋចំនួន ១,៥៥លាននាក់ និងបានផ្តល់ឥណទានចំនួន ៥,១៦ពាន់លានដុល្លារសហរដ្ឋអាមេរិកនៅទូទាំងប្រទេសនិងលើគ្រប់វិស័យនៃខឿនសេដ្ឋកិច្ចជាតិ។ សម្រាប់ខេត្តរតនគិរី ប្រជាជនប្រមាណ៦៥% បានទទួលសេវាហិរញ្ញវត្ថុ ពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ដែលនេះបញ្ជាក់ពីវិសាលភាពនៃការផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដល់ទីជនបទដាច់ស្រយាល ជាពិសេសបងប្អូនជនជាតិភាគតិច ដើម្បីចូលរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចជាតិ។

ស្របគ្នានេះដែរ **លោក តូច ចៅចេក** បានបន្ថែមថា៖ «ការពង្រីកវិសាលភាពនៃការផ្តល់សេវាហិរញ្ញវត្ថុនេះ បានជួយឱ្យគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងខេត្តរតនគិរី ផ្តល់ការងារដល់សិស្ស និស្សិត និងយុវជនក្នុងខេត្ត និងបានផ្តល់ជាប្រភពទុនដែលមានអាត្រាការប្រាក់ទាបដើម្បីឱ្យប្រជាពលរដ្ឋយកទៅវិនិយោគក្នុងវិស័យនានា និងបានចូលរួមចំណែកក្នុងការជំរុញសេដ្ឋកិច្ចក្នុងខេត្តរតនគិរីឱ្យមានការរីកចម្រើនផងដែរ»។ លោកបានបញ្ជាក់ផងដែរថា ស្ថិរភាពនិងភាពរឹងមាំ នៃវិស័យធនាគារ និងហិរញ្ញវត្ថុ គឺមិនអាចកើតមានទេ ប្រសិនបើគ្មានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធ។ លោកក៏បានផ្តល់អនុសាសន៍ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងខេត្តរតនគិរី បន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋានក្នុងខេត្ត ក្នុងការបន្តចូលរួមពង្រឹងការអប់រំដល់ប្រជាពលរដ្ឋ និងកិច្ចគាំពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ប្រកបដោយភាពទន់ភ្លន់ និងការទទួលខុសត្រូវខ្ពស់។

**ឯកឧត្តម ខិន ណៃឡុ** បានលើកឡើងអំពីគុណតម្លៃសន្តិភាព ដែលជំរុញឱ្យមានការអភិវឌ្ឍ និងរីកចម្រើនលើគ្រប់វិស័យ រួមទាំងវិស័យធនាគារ និងបានលើកឡើងអំពីប្រវត្តិនៃការកសាងឡើងវិញនៃវិស័យធនាគារ និងតួនាទីយ៉ាងសំខាន់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ ដើម្បីបង្កើត និងពង្រីកអាជីវកម្មរបស់ខ្លួន ព្រមទាំងបានជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងត្រូវមានការប្រុងប្រយ័ត្ន ចំពោះការឆបោកផ្នែកហិរញ្ញវត្ថុ។ ឯកឧត្តម អភិបាលរងខេត្តក៏បានបញ្ជាក់បន្ថែមថា វិស័យធនាគារ និងហិរញ្ញវត្ថុ នៅខេត្តរតនគិរី បានរួមចំណែកយ៉ាងសកម្ម ក្នុងការលើកស្ទួយកម្រិតជីវភាពរស់នៅ របស់ប្រជាជននៅទូទាំងខេត្ត មិនថានៅទីរួមខេត្ត ក្រុង ស្រុក ឃុំ ភូមិ ហើយជាពិសេសការផ្តល់សេវាហិរញ្ញវត្ថុ ជូនដល់បងប្អូនជនជាតិភាគតិចផងដែរ។ ទន្ទឹមនឹងភាពរីកចម្រើនរបស់វិស័យ **លោកជំទាវ ឱក នីតា** និង**លោក តូច ចៅចេក** ក៏បានរំលេចពីបញ្ហាប្រឈមមួយចំនួនដែលបាននិងកំពុងកើតឡើងនៅក្នុងខេត្តរតនគិរីផងដែរ រួមមានដូចជា ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជននៅមានកម្រិត ដែលជាហេតុនាំឱ្យការប្រើប្រាស់ឥណទានមិនមានប្រសិទ្ធភាព

ប្រជាជននៅមិនទាន់យល់ច្បាស់អំពីប្រភេទនៃប័ណ្ណកម្មសិទ្ធិដីធ្លី និងការប្រើប្រាស់សម្រាប់ជាទ្រព្យធានាបំណុល ព្រមទាំងសមត្ថភាពរបស់បុគ្គលិកប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុក្នុងខេត្តរតនគីរី នៅមានកម្រិត។

បញ្ហាប្រឈមទាំងនេះគឺបាននិងកំពុងដោះស្រាយតាមរយៈការបានដាក់ឱ្យអនុវត្តនូវគំនិតផ្តួចផ្តើមសំខាន់ៗមួយចំនួនក្នុងការបន្តអភិវឌ្ឍន៍វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ព្រមទាំងការការពារអតិថិជន។ ក្នុងនោះរួមមានដូចជា៖ ក្រមប្រតិបត្តិវិស័យធនាគារ និងហិរញ្ញវត្ថុ, ការដាក់ចេញនូវស្តង់ដាកិច្ចសន្យាឥណទាន និងខថែងស្តង់ដាកិច្ចសន្យាឥណទាន, ពង្រឹងកិច្ចការពារអតិថិជន និងការដាក់ដំណើរការយន្តការបណ្តឹងតវ៉ា លេខបណ្តឹងតវ៉ា, ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍, ការបោះផ្សាយនូវបញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មពីធនាគារជាតិនៃកម្ពុជា និងសៀវភៅស្វែងយល់លុយ, ការផលិតអត្ថបទអប់រំ កិច្ចពិភាក្សាពីអ្នកជំនាញ វីដេអូអប់រំខ្លីៗដែលធ្វើការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម ជាដើម ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ឱ្យបានទូលំទូលាយ៕

**សមាគមធនាគារនៅកម្ពុជា**

**សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែម៖
លោក សុខ ចាន់
នាយកផ្នែកបរិយាបន្នហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈនៃសមាគមធនាគារនៅកម្ពុជា
លេខទំនាក់ទំនង៖ ០៩២ ៦៨៣ ៣៣០
លោក កាំង តុងងី
ប្រធាននាយកដ្ឋានទំនាក់ទំនងនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
លេខទំនាក់ទំនង៖ ០១២ ៩៥៤ ២៤៧